**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ ០៧.សរ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានកិច្ចការរដ្ឋបាល
ចូល
លេខ...២៨៨៩...
ថ្ងៃទី.០៤...០៥...១៨...
បញ្ជូន.........

# សារាចរ
## ស្តីពី
## ការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ

អនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨, អនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាននិងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ និងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ ៣០ បប. ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងនីតិបុគ្គលសាធារណៈ ដែលជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ត្រូវរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋទាំងអស់ ដែលស្ថិតក្រោមការកាន់កាប់និងប្រើប្រាស់ដោយអង្គភាពរបស់ខ្លួន ដែលរួមមានទាំងអចលនវត្ថុ និងចលនវត្ថុ ហើយបញ្ជូនបញ្ជីសារពើភណ្ឌទាំងនោះមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីតម្កល់ទុក និងធ្វើការពិនិត្យតាមដាន ព្រមទាំងរាយការណ៍ជាទៀងរាល់ឆ្នាំនូវលទ្ធផលស្តីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ជូនប្រមុខរាជរដ្ឋាភិបាល តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី។

ក្នុងការអនុវត្តកន្លងមក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងនិងចាត់ចែងទ្រព្យសម្បត្តិរដ្ឋ បានខិតខំពង្រឹងការគ្រប់គ្រង និងការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដោយបានចេញផ្សាយនូវលិខិតបទដ្ឋានគតិយុត្ត និងបានចុះធ្វើការណែនាំផ្សព្វផ្សាយដល់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ជាប្រចាំ ក្នុងការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ក្នុងគោលបំណងពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ឱ្យកាន់តែមានប្រសិទ្ធភាព និងគណនេយ្យភាព ព្រមទាំងរួមចំណែកដល់ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគម្រោងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ប្រកបដោយគុណភាព គណនេយ្យភាព ប្រសិទ្ធភាព តម្លាភាព និងស័ក្តិសិទ្ធភាព។

ក៏ប៉ុន្តែ រាជរដ្ឋាភិបាលពិនិត្យឃើញថា កន្លងមក ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងនីតិបុគ្គលសាធារណៈជាច្រើន ដែលជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ មិនបានបញ្ចប់ការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់អង្គភាពខ្លួនឱ្យបានទាន់ពេលវេលាកំណត់នៅតាមឆ្នាំនីមួយៗឡើយ ហើយម្យ៉ាងវិញទៀត ក្នុងបញ្ជីសារពើភណ្ឌទ្រព្យ

សម្បត្តិរដ្ឋ ដែលបានរៀបចំរួច ក៏នៅខ្វះចន្លោះទិន្នន័យមួយចំនួនដូចជា វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ការកំណត់តម្លៃអចលនវត្ថុ និងចលនវត្ថុដែលជាទ្រព្យសម្បត្តិរដ្ឋ ជាដើម។

អាស្រ័យហេតុនេះ ដើម្បីពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឱ្យកាន់តែមានប្រសិទ្ធភាព ក៏ដូចជាធានាឱ្យបាននូវការអនុវត្តបានពេញលេញ គ្រប់ជ្រុងជ្រោយ និងទាន់ពេលវេលាកំណត់ រាជរដ្ឋាភិបាលដាក់ចេញនូវវិធានការដល់គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងនីតិបុគ្គលសាធារណៈដែលជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋទាំងអស់ ដើម្បីអនុវត្ត ដូចខាងក្រោម÷

១-អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវទទួលខុសត្រូវចំពោះមុខរាជរដ្ឋាភិបាល ក្នុងការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋជារៀងរាល់ឆ្នាំឱ្យបានត្រឹមត្រូវគ្រប់ចំនួន និងចប់សព្វគ្រប់នៅក្នុងត្រីមាសទី១ នៃឆ្នាំបន្ទាប់។ ការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវអនុវត្តតាមទម្រង់ចំនួនពីរប្រភេទ រួមមាន÷

**ទម្រង់ទី១**÷ ជាសៀវភៅបញ្ជីសារពើភណ្ឌកត់ត្រាលម្អិតនូវទ្រព្យសម្បត្តិរដ្ឋទាំងអស់ ដែលត្រូវធ្វើឡើងក្នុងរយៈពេល ០៥ (ប្រាំ)ឆ្នាំម្តង ហៅថា "**ឆ្នាំគោល**"។ កន្លងមក បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំគោល ធ្លាប់ត្រូវបានរៀបចំចំនួន ០២ ដង រួចមកហើយ ពោលគឺនៅឆ្នាំ២០០៤ និងឆ្នាំ២០០៩ ហើយសៀវភៅបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំគោលសម្រាប់រយៈពេល ០៥ ឆ្នាំ បន្ទាប់ នឹងត្រូវរៀបចំនៅរៀងរាល់ប្រាំឆ្នាំម្តងៗជាបន្តបន្ទាប់។ ទ្រព្យសម្បត្តិនីមួយៗ ដែលកត់ត្រាក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំគោល ត្រូវបំពេញទិន្នន័យរបស់ទ្រព្យសម្បត្តិនីមួយៗ នេះឱ្យបានពេញលេញ និងគ្រប់ជ្រុងជ្រោយ ដោយអនុលោមតាមបែបបទ នីតិវិធី និងទម្រង់គំរូរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ទម្រង់ទី២**÷ ជាតារាងកើនឡើងនិងថយចុះនូវទ្រព្យសម្បត្តិរដ្ឋ ដែលត្រូវធ្វើឡើងក្នុងឆ្នាំនីមួយៗ ក្នុងចន្លោះរយៈពេល០៥ (ប្រាំ) ឆ្នាំ នៃឆ្នាំគោល។ អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ត្រូវធ្វើតារាងប្រៀបធៀបនៃការកើនឡើង ឬថយចុះទ្រព្យសម្បត្តិរដ្ឋក្នុងឆ្នាំនីមួយៗ ដោយអនុលោមតាមបែបបទ នីតិវិធី និងទម្រង់គំរូរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ ដែលរៀបចំរួច ត្រូវផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំនួន ០២ (ពីរ) ច្បាប់ យ៉ាងយូរនៅដំណាច់ត្រីមាសទី១ នៃឆ្នាំបន្ទាប់ ដើម្បីតម្កល់ទុក និងធ្វើការពិនិត្យតាមដាន ព្រមទាំងរាយការណ៍ជារៀងរាល់ឆ្នាំនូវលទ្ធផលស្តីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ជូនប្រមុខរាជរដ្ឋាភិបាល តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី។

ទ្រព្យសម្បត្តិរបស់រដ្ឋទាំងអស់ ដែលកំពុងស្ថិតនៅក្រោមការកាន់កាប់របស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ តាមបែបបទ និងនីតិវិធី ដែលត្រូវកំណត់ក្នុងប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ទ្រព្យសម្បត្តិរដ្ឋទាំងអស់អាចជាកម្មវត្ថុនៃការចាត់ចែងបាន លុះត្រាតែទ្រព្យសម្បត្តិទាំងនោះត្រូវបានចុះក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ។

២-អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ត្រូវកត់ត្រាទ្រព្យសម្បត្តិរដ្ឋទាំងអស់ដែលស្ថិតនៅក្រោមការកាន់កាប់ និងប្រើប្រាស់របស់ខ្លួន នូវអចលនវត្ថុនិងចលនវត្ថុទាំងអស់ រួមទាំងអចលនវត្ថុ និងចលនវត្ថុ ដែលជាអំណោយរបស់ដៃគូអភិវឌ្ឍន៍ មានដូចជា សមិទ្ធផល ឧបករណ៍ សម្ភារៈនៃគម្រោង ដែលបានបញ្ចប់ហើយត្រូវបានផ្ទេរជូនរដ្ឋ ទ្រព្យសម្បត្តិដែលទទួលបានពីការដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ទ្រព្យសម្បត្តិរដ្ឋដែលជាកម្មវត្ថុនៃការវិនិយោគ ដូចជាទីតាំងផ្សារ ចំណត កំពង់ចម្លង សត្តឃាតដ្ឋានជាដើម និងទ្រព្យសម្បត្តិដែលជាអំណោយរបស់សប្បុរសជននានាផ្តល់ជូនអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ សម្រាប់ប្រើប្រាស់ជាទ្រព្យសម្បត្តិរបស់រដ្ឋ។ ទ្រព្យសម្បត្តិ

រដ្ឋទាំងអស់នេះ ត្រូវចុះក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដោយមានការចូលរួមត្រួតពិនិត្យ ក្នុងការប្រគល់-ទទួលពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិរដ្ឋ។

៣-នៅក្នុងកិច្ចដំណើរការអនុវត្តគម្រោងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) តម្រូវឱ្យមានការបញ្ចូលទិន្នន័យតម្លៃ នៃទ្រព្យសម្បត្តិរដ្ឋទាំងអស់ទៅក្នុងគណនីសាធារណៈរបស់រដ្ឋ ដែលទាមទារជាចាំបាច់ឱ្យមានការវាយតម្លៃនិងកំណត់តម្លៃទ្រព្យសម្បត្តិរដ្ឋទាំងអស់។ ហេតុដូច្នេះ អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋទាំងអស់ ជាពិសេសគណៈកម្មការបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋប្រចាំក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងនីតិបុគ្គលសាធារណៈ ទាំងអស់ ត្រូវរួមសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក្នុងការចុះធ្វើការវាយតម្លៃ និងកំណត់តម្លៃទ្រព្យសម្បត្តិរដ្ឋទាំងអស់។ ការវាយតម្លៃ និងការកំណត់តម្លៃអចលនវត្ថុត្រូវឈរលើមូលដ្ឋាននៃតម្លៃគិតពន្ធលើអចលនទ្រព្យរបស់អគ្គនាយកដ្ឋានពន្ធដារ ឬតម្លៃទីផ្សារជាក់ស្តែង ឬតាមមធ្យោបាយផ្សេងទៀតតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ដើម្បីធានាបាននូវប្រសិទ្ធភាពនិងគណនេយ្យភាព នៃការវាយតម្លៃនិងកំណត់តម្លៃទ្រព្យសម្បត្តិរដ្ឋទាំងអស់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបញ្ជូនមន្ត្រីជំនាញ ទៅតាមគ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងនីតិបុគ្គលសាធារណៈទាំងអស់ ដើម្បីចូលរួមជាមួយគណៈកម្មការបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ធ្វើការកំណត់តម្លៃទ្រព្យសម្បត្តិរដ្ឋទាំងអស់ និងបញ្ចូលទិន្នន័យតម្លៃទាំងនោះ ទៅក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។

មូលដ្ឋាននៃការកំណត់តម្លៃទ្រព្យសម្បត្តិរដ្ឋសម្រាប់បញ្ចូលទៅក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ មិនត្រូវធ្វើជាមូលដ្ឋានក្នុងការកំណត់តម្លៃក្នុងកិច្ចសន្យាចាត់ចែងទ្រព្យសម្បត្តិរដ្ឋឡើយ ដែលមូលដ្ឋាននេះត្រូវកំណត់ដោយឡែកតាមករណីជាក់ស្តែង តាមការកំណត់របស់រាជរដ្ឋាភិបាល ឬក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៤-រាល់ការជម្រះទ្រព្យសម្បត្តិរដ្ឋទាំងអស់ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវអនុលោមទៅតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន និងត្រូវស្នើសុំគោលការណ៍សម្រេចពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

បែបបទ នីតិវិធី និងទម្រង់នៃការជម្រះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៥- អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ត្រូវរៀបចំធ្វើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលើទ្រព្យសម្បត្តិរដ្ឋជាអចលនវត្ថុទាំងអស់ ស្ថិតនៅក្រោមការកាន់កាប់ និងប្រើប្រាស់របស់ខ្លួន ឱ្យបានឆាប់រហ័ស និងតាមពេលវេលាកំណត់ ដោយសហការជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ គ្រប់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋទាំងអស់ ត្រូវបញ្ចូលវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ដែលរៀបចំរួច ទៅក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។

៦-អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋទាំងអស់ ត្រូវរៀបចំធ្វើតារាងបច្ចុប្បន្នភាពបញ្ជីជួលទ្រព្យសម្បត្តិរដ្ឋ បញ្ជីសម្បទានដីសេដ្ឋកិច្ច បញ្ជីសម្បទានដីសង្គមកិច្ច បញ្ជីសម្បទានរ៉ែ និងបញ្ជីសម្បទានទ្រព្យសម្បត្តិរដ្ឋដទៃទៀត ឱ្យបានឆាប់រហ័ស រួចបញ្ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល ចំនួន ០២ (ពីរ) ច្បាប់ ដើម្បីតម្កល់ទុក និងតាមដាននូវការប្រើប្រាស់និងចាត់ចែងទ្រព្យសម្បត្តិរដ្ឋទាំងអស់។ បញ្ជីនេះ ត្រូវរៀបចំជាប្រចាំឆ្នាំនៅរៀងរាល់ត្រីមាសទី១ នៃឆ្នាំបន្ទាប់ ដោយត្រូវចាប់ផ្តើមអនុវត្តសម្រាប់ឆ្នាំ២០១៣ តទៅ។

៧-អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋទាំងអស់ ត្រូវយកបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំកន្លងទៅ មកប្រគល់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិរដ្ឋ នៅពេលរៀបចំថវិកាប្រចាំឆ្នាំនីមួយៗ។ ក្នុងករណីដែលអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ណាមួយ មិនបានបំពេញលក្ខខណ្ឌនេះទេ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចាត់វិធានការជាបន្ទាន់ ក្នុងការរឹតបន្តឹងខាងចំណាយ របស់សាមីអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ នោះ តាមការជាក់ស្តែង។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត និងនីតិបុគ្គលសាធារណៈ ដែលជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋទាំងអស់ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់ ហើយរាយការណ៍អំពីលទ្ធផលនៃការអនុវត្តសារាចរនេះ ជូនរាជរដ្ឋាភិបាលវិញ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

លេខ ៤៤១ ចល.កសក

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើមនិងបញ្ជូនមក ៖

-ឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ "ដើម្បីជូនជ្រាប"

-ឯកឧត្តម លោក លោកស្រីប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-លោកប្រធានមន្ទីរកសិកម្មរាជធានី ខេត្ត "ដើម្បីជ្រាបនិងមុខការ"។

រាជធានីភ្នំពេញ ,ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០១៤

ត.ប រដ្ឋមន្ត្រី

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អគ្គលេខាធិការ